ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation – Religion – King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៥៧ ព.ណ.[illegible]

ភ្នំពេញ, ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៤

# ប្រកាសស្តីពី
# ការកែសម្រួលនីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ, វិក័យប័ត្រពាណិជ្ជកម្ម, អាជ្ញាប័ណ្ណនាំចេញ តាមជើងយន្តហោះ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
## និងជាប្រធានអនុគណៈកម្មការសំរបសំរួលពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រិត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម .
- បានឃើញអនុក្រិត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម .
- យោងតាមស្មារតីអង្គប្រជុំអនុគណៈកម្មការសំរបសំរួលពាណិជ្ជកម្ម ដែលដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៤ ប្រារព្ធធ្វើនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា .
- ដើម្បីសំរួលការងារនាំចេញទំនិញសំលៀកបំពាក់ និង វាយនភ័ណ្ឌ តាមជើងយន្តហោះ

## សំរេច

**ប្រការ ១ :** ត្រូវបានកែសំរួលបំពេញបន្ថែមប្រការ ១ ចំណុច "ឃ" នៃប្រកាសលេខ ១៥៩ MoC/M2004 ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០០៤ ស្តីពី នីតិវិធីចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ C/O (Certificate of Origin). វិក័យប័ត្រពាណិជ្ជកម្ម C/I (Commercial Invoice). អាជ្ញាប័ណ្ណនាំចេញ E/L (Export License) ចំពោះមុខទំនិញដែលត្រូវដឹកជញ្ជូនតាមជើងយន្តហោះ ដោយត្រូវផ្អែកតាមនិតិវិធីដូចខាងក្រោមនេះ ÷

ក- នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស, នាយកដ្ឋានអាស៊ាន និងអង្គការ


Ministry of Commerce, # 20 A & B Preah Norodom Boulevard, Phnom Penh (Kingdom of Cambodia)
Hand Phone : 016 861 616 - 016 988 858 - 016 818 825 - ( 023 ) 725 585 Facsimile : ( 855 ) 23 426 396

អន្តរជាតិ អាចចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O). វិក័យប័ត្រពាណិជ្ជកម្ម (C/I). អាជ្ញាប័ណ្ណនាំចេញ (E/L) តាមជើងយន្តហោះ ជូនក្រុមហ៊ុនដោយផ្អែកតាមវិក័យប័ត្រ (Invoice) និង តារាងបញ្ជាក់ការវេចខ្ចប់ (Packing List) របស់ក្រុមហ៊ុន ។

ខ- មន្ត្រីនាយកដ្ឋានកាំកុងត្រូលត្រូវសហការជាមួយមន្ត្រីគយ និងរដ្ឋាករ ដើម្បីធ្វើការត្រួតពិនិត្យទំនិញដែលនាំចេញតាមជើងយន្តហោះ ដោយផ្ទៀងផ្ទាត់ជាមួយនឹងឯកសារ C/O, C/I, E/L ដែលបានចេញជូនខាងលើ ។

គ- នៅពេលទំនិញបានចេញផុតពីកម្ពុជាហើយ. មន្ត្រីកាំកុងត្រូលត្រូវបញ្ជូនកំណត់ហេតុត្រួតពិនិត្យរួមរបស់ខ្លួនទៅជូននាយកដ្ឋានជំនាញខាងលើ ដើម្បីមានមូលដ្ឋានត្រួតពិនិត្យ-ផ្ទៀងផ្ទាត់ចំពោះលក្ខខ័ណ្ឌបច្ចេកទេសនានាក្នុងការផលិតរបស់ក្រុមហ៊ុន និង ការអនុវត្តនីតិវិធានប្រភពដើមទំនិញ ។

ឃ-ក្រុមហ៊ុននាំចេញត្រូវរូតរះអោយបានទាន់ពេលវេលាដើម្បីផ្ញើរជូននាយកដ្ឋានជំនាញពាក់ព័ន្ធ នូវឯកសារយោងដទៃ ទៀតដើម្បីភ្ជាប់ជាឯកសារផ្ទៀងផ្ទាត់ រួមមាន ÷

- អញ្ញាត្តិប័ណ្ណដឹកជញ្ជូនតាមជើងយន្តហោះ (Air Waybill )
- កិច្ចសន្យាទិញ-លក់ (Sale Contract)
- មូលប្បទានប័ត្រ សំរាប់សោហ៊ុយរដ្ឋបាល ឬ សំរាប់កំរៃកូតានាំចេញ ឬ កំរៃនាំចេញ

**ប្រការ ២ :** អគ្គាធិការ, អគ្គនាយកបច្ចេកទេស, ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ , ប្រធាននាយកដ្ឋានកាំកុងត្រូល នាយិការខុទ្ទកាល័យ ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ជ.ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**គឹម_ស៊ីថន**

**ចម្លងជូន :**

-ខុទ្ទកាល័យ **សម្តេចនាយករដ្ឋមន្ត្រី**
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង ជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សោ ខេង**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
-ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
-ស្ថានឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
-អគ្គប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
-ទីចាត់ការគយ និង រដ្ឋាករ
-សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ